# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):07-Sep-2012, 15:23
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨"

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | នួន ជា |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម **យ៉ា សុខន** | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |

*០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

ចៅក្រម **យូរ ឧត្តរា**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីការពារក្តី៖**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

*០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹងសំណើ ដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី (“មេធាវីការពារក្តី”) ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីការប្រាស្រ័យទាក់ទងជាមួយសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨[1] (“សំណើ”) ដូចខាងក្រោម។

2. សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើសុំព័ត៍មានបន្ថែមទៀតពី ក.ស.ច.ស ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ទេ។ ប៉ុន្តែសហព្រះរាជអាជ្ញា សូម ជំទាស់ចំពោះសំអាងហេតុជាច្រើនដែលមេធាវីការពារក្តីបានលើកឡើងដើម្បីគាំទ្រសំណើរបស់ខ្លួន ដែលស្នើសុំឲ្យមានការជំទាស់ទៅនឹងសុពលភាព និងទម្ងន់នៃសក្ខីកម្មរបស់ អឿន តាន និងការអះអាងថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អៀង សារី ត្រូវបានរំលោភបំពាន។ ជាការពិត វោហារសាស្ត្រដែលចម្លែកខុសគេ និងគ្មានការគាំទ្ររបស់មេធាវីការពារក្តី បានធ្វើឲ្យគេយល់ខុសដើម្បី ឲ្យព័ត៍មានដែលគាត់ ស្នើសុំត្រូវបាន ទទួល យក។

## II. ឧទ្ទិករណ៍

### ក. សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើសុំព័ត៍មានបន្ថែម ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ឡើយ

3. កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ តាមការបញ្ជាក់របស់សាក្សី អឿន តាន ថាគាត់ធ្លាប់ត្រូវ បានធ្វើសម្ភាសន៍ដោយអ្នកស៊ើបអង្កេតរបស់ កសចស ក្នុងរយៈពេលមួយថ្ងៃពេញនៅមុនការថតខ្សែអាត់ នៃការធ្វើសម្ភាសន៍របស់គាត់ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានធ្វើការស្នើសុំដោយផ្ទាល់មាត់ ដែលមានដូចជា៖ “យើងខ្ញុំគិតថា វាជាការសមស្របដែលគួរតែ៖ ទី១ បានទទួលនូវប្រតិចារិកនៃការធ្វើសម្ភាសន៍ កាលពីថ្ងៃទី៩ ខែតុលានោះ ចំនួនមួយច្បាប់ ហើយបន្ទាប់មកប្រហែលជាត្រូវ

---

[1] **E224** សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេង នានាទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ចុះថ្ងៃទី ២៩ ខែ សីហាឆ្នាំ ២០១២ (បន្ទាប់ពីនេះយោងដោយ “សំណើ”)។ បានជូនដំណឹងនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១២។

ពិចារណា ក្នុងការស្នើសុំពី កសចស នូវការបញ្ជាក់បំភ្លឺណាមួយ អំពីខ្សែអាត់ថតសម្លេងកាលពី ថ្ងៃទី៨ តុលា [និង] ថាតើខ្សែអាត់ថតសម្លេងនោះមានអត្ថិភាពដែរឬទេ? "[2]។ ហេតុដូច្នេះ មេធាវីការពារ ក្តីបំប្លែងគោលជំហររបស់សហព្រះរាជអាជ្ញា នៅពេលដែលមេធាវីការពារក្តីបានលើកឡើងថា សហព្រះរាជអាជ្ញាចាត់ទុកសេចក្តីបញ្ជាក់បំភ្លឺពី កសចស ថា គឺ *មានលក្ខណៈចាំបាច់*ហើយក៏បានធ្វើ*សំណើ* ដោយផ្ទាល់មាត់មួយ សុំនូវការបញ្ជាក់បំភ្លឺនេះ [3]។

4. សហព្រះរាជអាជ្ញា កត់សំគាល់ឃើញថាប្រតិចារិកមួយផ្នែកនៃការធ្វើសម្ភាសន៍សាក្សីកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ[4]។ តាមដែលមើលឃើញ ប្រតិចារិកនោះបានបញ្ជាក់ថា មានការពិភាក្សាមួយជាមួយសាក្សីបានធ្វើឡើងនៅមុនថ្ងៃធ្វើសម្ភាសន៍នោះ[5]។ គោលជំហររបស់សហព្រះរាជអាជ្ញាចំពោះការបញ្ជាក់បំភ្លឺ គឺនៅដដែលដូចដែលបានបញ្ជាក់នៅក្នុងតុលាការ៖ វាជាការសមស្របចំពោះ អង្គជំនុំជម្រះ គួរពិចារណាក្នុងការស្វែងរកការបញ្ជាក់បំភ្លឺបន្ថែមទៀតពី កសចស ដោយសារតែបញ្ហានេះមិនទាន់មានភាពច្បាស់លាស់ទាំងស្រុងថា តើការសួរយកចម្លើយដែលធ្វើឡើងរវាង ក.ស.ច.ស និង អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ នោះ មានលក្ខណៈជាអ្វី? ទោះជាយ៉ាងណាក្តី សម្រាប់សំអាងហេតុដែលបានលើកឡើងខាងក្រោម ការបញ្ជាក់នេះមិនមាន "លក្ខណៈចាំបាច់" ដើម្បីធ្វើការវាយតម្លៃ លើទម្ងន់នៃសក្ខីកម្មរបស់ អឿន តាន ឬក៏ដើម្បីការពារ សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អៀង សារី ឡើយ។

5. ខណៈពេលដែលមេធាវីការពារក្តី មិនបានស្នើសុំឲ្យមានដំណោះស្រាយឲ្យហួសពីការបញ្ជាក់បំភ្លឺអំពីការប្រាស្រ័យទាក់ទងដែលបានធ្វើឡើងនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨[6] ដែលផ្នែកផ្សេងៗ ទៀតនៃសំណើបង្ហាញឲ្យឃើញពីអនិយ័តភាពផ្នែកនីតិវិធីបានកើតឡើង នៅក្នុងដំណាក់កាលស៊ើបអង្កេតដែលមានការ

---

[2] **E1/87.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ត្រង់ទំព័រ ៥៣ បន្ទាត់ ១២-១៦។

[3] **E224** សំណើ, កំណត់សម្គាល់លេខ ១ *ពីខាងដើម* ត្រង់ទំព័រ១ និង៣ (កថាខណ្ឌទី៥)។

[4] **D107/2.1** ប្រតិចារិកផ្នែកខ្លះនៃឯកសារខ្សែអាត់ថតសម្លេង D107/2R។

[5] *ដូចគ្នានឹងខាងលើត្រង់កន្លែងដដែល* ទំព័រ៤។

[6] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់ទំព័រ៧-៨។

ជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬសុចរិតភាពដំណើរការរឿងក្តី។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា កាលៈទេសៈ នៃការស្តាប់ចម្លើយរបស់ អឿន តាន ពុំបានផ្តល់ឲ្យមានការកកើតឡើងនៃការទាមទារដែលអាចអនុវត្តបានទាក់ទិននឹងកំហុសនីតិវិធីឡើយ។ សំអាងហេតុនានាដែលច្រានចោលការអះអាង ផ្នែកនីតិវិធីដែលបាន លើកឡើងថា បានកើតឡើងនៅដំណាក់កាលស៊ើបអង្កេត ត្រូវបានលើកបង្ហាញ បន្ថែមទៀតដូចខាងក្រោម។

## ខ. ពុំមានអំណះអំណាងស្របច្បាប់អំពីផលប៉ះពាល់មិនល្អលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អៀង សារី ឡើយ

6. ទោះជាមានការសួរសាក្សីបន្ថែមទៀត ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ក៏ដោយ គឺពុំមានការ "ប៉ះពាល់ដល់លទ្ធភាពរបស់លោក អៀង សារី ក្នុងការពិនិត្យភ័ស្តុតាងដាក់បន្ទុក និងការការពារក្តីឡើយ"[7] ពីព្រោះ៖ ១) "កំហុសនីតិវិធី" ណាមួយត្រូវបានលុបលាងហើយ។ ២) អឿន តាន បានផ្តល់សក្ខីកម្មនៅក្នុងតុលាការ ដែលមេធាវីការពារក្តីអាច និងព្រមទាំងបានត្រួតពិនិត្យភ័ស្តុតាងរបស់ខ្លួនផងដែរ និង ៣) កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីការសម្ភាសន៍ និងបានអនុលោមតាមវិធាន នានារបស់ អ.វ.ត.ក។

### *i. កំហុសនីតិវិធីណាមួយដែលបានលើកឡើងត្រូវបានលុបលាងរួចហើយ*

7. អនុលោមតាមវិធានផ្ទៃក្នុង បណ្តឹងសុំមោឃភាពទាក់ទងនឹងកំហុសនីតិវិធីនៅក្នុងពេលស៊ើបសួរ អាចដាក់បានតែនៅមុនពេលចេញដីកាដំណោះស្រាយតែប៉ុណ្ណោះ។ ក្នុងអំឡុងពេលកិច្ចស៊ើបសួរ អនុលោមតាមវិធាន៧៦ ជនជាប់ចោទមានសិទ្ធិដាក់បណ្តឹងសុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬកិច្ចស៊ើបសួរដ៏ទៃទៀត។ វិធាន ៧៤(ខ) ចែងថា "មានតែ" អង្គបុរេជំនុំជម្រះទេដែល "មានសមត្ថកិច្ចផ្តាច់មុខ" ដើម្បីពិនិត្យមើលបណ្តឹងបែបនេះ។ វិធាន៧៦(៧) ចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយលុបលាងរាល់កំហុសនីតិវិធីក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឬអង្គជំនុំ

[7] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ៩។

ជម្រះតុលាការកំពូលឡើយ”[8]។ អាស្រ័យហេតុនេះ វិធាន អ.វ.ត.ក បញ្ជាក់យ៉ាងច្បាស់ថា ការជំទាស់ទៅនឹងដំណើការនីតិវិធីក្នុងការស៊ើបសួរ ត្រូវបានកំណត់ឲ្យធ្វើបានមុនដំណាក់កាលបុរេជំនុំជម្រះតែប៉ុណ្ណោះ។

8. អង្គជំនុំជម្រះសាលាដំបូង “មិនមែនជាសាលាឧទ្ធរណ៍ ហើយក៏មិនមែនជាស្ថាប័នដែលត្រូវត្រួតពិនិត្យឡើងវិញ ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះទេ”[9]។ អាស្រ័យហេតុនេះ “ជាទូទៅ នៅក្នុងដំណាក់កាលស៊ើបសួរ ការជំទាស់ទៅនឹងដំណើរការនីតិវិធី ឬសេចក្តីសម្រេចនានា ដែលបានធ្វើឡើងដោយ ស.ច.ស និងអង្គបុរេជំនុំជម្រះក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ត្រូវតែលើកឡើងនៅចំពោះមុខតុលាការដែលមានសមត្ថកិច្ច មុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ”[10]។

9. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា មានការលើកលែងចំពោះវិធាន៧៦(៧) “ក្នុងករណីភាគីអាចបង្ហាញថា ពួកគេមិនមានឱកាសរកឲ្យឃើញនូវភាពមិនប្រក្រតីនានាដែលបានលើកឡើងនៅមុនពេលបើកសវនាការលើអង្គសេចក្តី ឬក្នុងករណីមានភាពចាំបាច់ ដើម្បីគាំពារភាពយុត្តិធម៌នៃកិច្ចដំណើការនីតិវិធីជំនុំជម្រះក្តី”[11]។ គ្មានការលើកលែងណាមួយផ្សេងក្រៅពីការលើកលែងដែលបានលើកឡើងខាងលើនេះអាចអនុវត្តបាននៅទីនេះទេ។ មេធាវីការពារក្តីមានពេលវេលាពេញបរិបូរដើម្បីរកឲ្យឃើញនូវបញ្ហាដែលជាក្តីកង្វល់របស់ពួកគេដូចបានលើកឡើងក្នុងសំណើ ដែលមេធាវីការពារក្តីបានទទួលស្គាល់ថាបានដឹងតាមរយៈ ការស្តាប់ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយ[12]។ អង្គជំនុំជម្រះ បានធ្វើការកត់សម្គាល់ពីមុនថា៖

---

[8] *សូមមើលផងដែរ* ឯកសារ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២។

[9] ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3, E82, E88 និង E92), ៩ កញ្ញា ២០១១ (ចាប់ពីនេះតទៅហៅថា “សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ”), កថាខណ្ឌ ១៨។

[10] កំណត់សម្គាល់*ខាងដើម* ត្រង់កថាខណ្ឌ១៥។

[11] ឯកសារ **E142/3** សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ នួន ជា ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៧ (បន្ទាប់ពីនេះតទៅហៅថា “សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី”)។

[12] ឯកសារ **E224** សំណើ, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌ១ និង ១០។

*ទាមងខ្សែអាត់សំឡេង និងទាំងកំណត់ហេតុស្តាប់ចម្លើយ ត្រូវបានដាក់ចូលក្នុងសំណុំរឿងជាបន្តបន្ទាប់ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ហើយដូច្នេះ ភាគីមានលទ្ធភាពពិនិត្យមើលឯកសារទាំងនោះបាន (ទាំងអ្នកចេះភាសាខ្មែរ ភាសាអង់គ្លេស និង/ឬភាសាបារាំង) ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ*[13] ។

10. សហព្រះរាជអាជ្ញា កត់សម្គាល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយសាក្សី អឿន តាន ទាំងបីភាសា ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ ត្រូវបានដាក់ក្នុងសំណុំរឿង នៅថ្ងៃទី៤ វិច្ឆិកា ឆ្នាំ២០០៨។ មេធាវីការពារក្តីគួរតែ អាចពិនិត្យមើលឡើងវិញ នូវខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍ជាមួយ អឿន តាន នៅក្នុងអម្លុងនៃកិច្ចស៊ើបសួរ។ ហេតុដូចនេះមិនមានមូលហេតុត្រឹមត្រូវតាមច្បាប់ណាមួយចំពោះការខកខានមិនបានលើកពីបញ្ហានេះនៅក្នុងពេលសមស្របទាំងនេះ ហើយអង្គជំនុំជម្រះសាលាដំបូងមិនគួរ "ពិនិត្យពិចារណាលើបញ្ហាផ្សេងៗដែលបញ្ហាទាំងនេះគួរត្រូវបានលើកឡើងនៅ ក្នុងដំណាក់កាលនៃការស៊ើបសួរឡើយ"[14]។

*ii. សក្ខីកម្មរបស់សាក្សីរូបនេះនៅក្នុងពេលសវនាការ កែតម្រូវចំពោះកំហុសនីតិវិធីផ្សេងៗដូចដែលគេបានអះអាង នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដែលធ្វើឡើងដោយ កសចស និងការពារដល់សិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ជនជាប់ចោទ*

11. លើសពីនេះ ការលើកលែងចំពោះវិធាន៧៦(៧) មិនមានភាពចាំបាច់ក្នុងការការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីឡើយ។ ទោះជាមានកំហុសនីតិវិធីបានកើតចេញពីរបៀបណាមួយក្នុងពេលស្តាប់ចម្លើយ អឿន តាន ក៏ដោយក៏សាក្សីបានផ្តល់សក្ខីកម្មក្នុងតុលាការរួចហើយ ហើយក្រុមមេធាវីការពារក្តីមានឱកាសដ៏បរិបូរដើម្បីសួរដេញដោលអំពីខ្លឹមសារនៃសក្ខីកម្មរបស់គាត់ និងកិច្ចដំណើរការនីតិវិធី ក្នុងអំឡុងពេលស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស ផងដែរ[15] ។ អាស្រ័យហេតុនេះ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីរូបនេះ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ ត្រូវបានការពារគ្រប់គ្រាន់ហើយ។

---

[13] ឯកសារ **E142/3** សេចក្តីសម្រេចលើកំណត់ហេតុការស្តាប់ចម្លើយសាក្សី, កំណត់សម្គាល់*ខាងដើម* លេខ១២ ត្រង់កថាខណ្ឌ៦, ៨។

[14] ឯកសារលេខ**E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, កំណត់សម្គាល់លេខ១២ *ខាងដើម* ត្រង់កថាខណ្ឌទី៧។

[15] ឯកសារលេខ **E1/87.1** ប្រតិចារិកនៃដំណើការនីតិវិធីសវនាការ ទំព័រទី ២៦-៣៥ , ទំព័រទី ៤៥-៥១។

12. ក្នុងការច្រានចោលសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ផ្អែកលើវិធាន៣៥ អំពីចំណុចដែលមិនស្របគ្នាដោយអន្លើដែលត្រូវបានចោទប្រកាន់រវាងកំណត់ហេតុនៃការស្តាប់ចម្លើយ និងខ្សែអាត់សម្លេង អង្គជំនុំជម្រះសម្រេចថា "ទោះក្រោមកាលៈទេសៈបែបណាក្តី ក៏ក្រុមមេធាវីការពារក្តីនឹងទទួលបានការគាំពារថែមទៀតនូវលទ្ធភាពក្នុងការសួរសំណួរទៅសាក្សីនានានៅសវនាការ ស្តីពីចំណុចមិនស្របគ្នាដែលត្រូវបានចោទប្រកាន់ទាំងនោះ នៅពេលដែលចំណុចមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់ទាំងអស់នេះពាក់ព័ន្ធជាក់ស្តែងទៅនឹងការវាយតម្លៃភ័ស្តុតាងភរនីភាព ឬមួយទៅនឹងភាពចាំបាច់សម្រាប់ការការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីសវនាការ"[16] ។ ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តីដទៃទៀត ត្រូវបានអនុញ្ញាតឲ្យសួរដេញដោល អឿន តាន ជាលើកទីបីនៃរយៈពេលរបស់សាក្សីនៅលើវេទិកា។ ដូច្នេះនៅពេលនេះ ក្រុមមេធាវីការពារក្តីមិនអាចអះអាងគួរឲ្យជឿជាក់បានថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺមិនត្រូវបានការពារគ្រប់គ្រាន់ទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះឡើយ។

13. បន្ថែមលើនេះ ដូចដែលសាក្សី អឿន តាន នៅពេលនេះបានផ្តល់សក្ខីកម្មអស់រយៈពេលមួយថ្ងៃកន្លះនៅចំពោះមុខអង្គជំនុំជម្រះភាព មិនស្របគ្នាដោយអន្លើនៃកិច្ចដំណើរការនីតិវិធី ដែលបានចោទប្រកាន់ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ កសចស គឺប៉ះពាល់តែបន្តិចបន្តួច ឬ ពុំមានផលប៉ះពាល់អ្វីទាល់តែសោះ។ វាគឺជាសក្ខីកម្មដល់អង្គជំនុំជម្រះដែលមានរយៈពេលមួយថ្ងៃកន្លះ ដែលឥឡូវនេះ ជាភ័ស្តុតាង ចំបងនៅចំពោះមុខអង្គជំនុំជម្រះ។

*iii. កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវសក្ខីកម្មរបស់សាក្សី និង អនុលោមតាមវិធានរបស់ អ.វ.ត.ក*

14. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើការកត់សម្គាល់រួចមកហើយគឺថា "អនុលោមតាមទម្លាប់អនុវត្តទូទៅនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការស្តាប់ចម្លើយនៅចំពោះមុខ ក.ស.ច.ស ពុំមែនជាកំណត់ហេតុពេញលេញឡើយ ប៉ុន្តែវាជារបាយការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើងស្តីពីចម្លើយពាក់ព័ន្ធរបស់សាក្សី

[16] ឯកសារ **E142/3** សេចក្តីសម្រេចលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កថាខណ្ឌ ១៤។ *សូមមើលផងដែរ* **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កំណត់សម្គាល់លេខ១០, ត្រង់កថាខណ្ឌ១៩។

ដើមបណ្ដឹងរដ្ឋប្បវេណី ឬ ជនជាប់ចោទ”[17]។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានផងដែរថា វិធានផ្ទៃក្នុងនៃ អ.វ.ត.ក មិនបានកំណត់ថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវកត់ត្រាថិរវេលាពិតប្រាកដនៃការស្ដាប់ចម្លើយសាក្សី ឬការឈប់សម្រាកនៅចន្លោះពេលស្ដាប់ចម្លើយសាក្សីនីមួយៗ ឬតម្រូវឲ្យថតសម្លេង ឬថតវីដេអូ ពីការស្ដាប់យកចម្លើយសាក្សីនោះទេ[18]។

15. អាស្រ័យហេតុនេះ បណ្ដឹងរបស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងការខកខានរបស់អ្នកស៊ើបអង្កេត ដែលមិនបានកត់ត្រានូវគ្រប់ការប្រាស្រ័យទាក់ទងទាំងអស់ ដែលធ្វើឡើងជាមួយសាក្សីម្នាក់ៗ គឺពុំមែនជាការរំលោភទៅលើនីតិវិធីនៃវិធាន អ.វ.ត.ក ដែលធានាឲ្យអង្គជំនុំជម្រះត្រូវចាត់វិធានការនោះទេ[19]។ ទោះបីពុំតម្រូវឲ្យពួកគេធ្វើបែបនេះក៏ដោយក៏ការស្ដាប់ចម្លើយសាក្សីភាគច្រើនរបស់ ក.ស.ច.ស ត្រូវបានធ្វើឡើងដោយការថត ជាខ្សែអាត់សំឡេង ហើយខ្សែអាត់សំឡេងទាំងនោះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ហើយមេធាវី ការពារក្ដី និងភាគីដទៃទៀត ក៏អាចយកមកពិនិត្យបានដែរ។ ដូចដែលអង្គជំនុំជម្រះបានកត់សម្គាល់រួចមកហើយ គឺថាទម្លាប់អនុវត្តរបស់ ក.ស.ច.ស បែបនេះគឺ “មិនដូចគ្នាទៅនឹងការបង្អាក់កិច្ចស៊ើបសួរដោយចេតនាឡើយ”[20]។ ក្នុងករណីបច្ចុប្បន្ននេះ បើទោះបីជាមិនស្របគ្នានឹងការប៉ុនប៉ងដោយចេតនាដើម្បីបង្អាក់កិច្ចស៊ើបសួរណាមួយក្ដី ការពិតគឺថា ក្នុងពេល *ធ្វើសម្ភាសន៍ដែលបានថតសម្លេង* នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨នោះ អ្នកស៊ើបអង្កេត *បានអះអាង* ពីការពិតនៃការសន្ទនាគ្នាជាមុនជាមួយសាក្សីរូបនេះ ហើយបានបញ្ជាក់ថា ការសន្ទនាគ្នានោះ *មិនបានថតសម្លេងទេ*[21]។

16. លើសពីនេះទៀត មិនខ្វល់ថាតើអ្នកស៊ើបអង្កេតបានធ្វើការពិភាក្សាជាមុនជាមួយ អឿន តាន ដោយពុំបានថតសម្លេងនោះទេ ក៏កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់អ្នកស៊ើបអង្កេតទាំង

---

[17] **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី, កំណត់សម្គាល់*ខាងលើ* លេខ១០ ត្រង់កថាខណ្ឌទី១១។

[18] **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី, កំណត់សម្គាល់*ខាងលើ* លេខ១០ ត្រង់កថាខណ្ឌ៦, កំណត់សម្គាល់ជើងទំព័រលេខ១៣។

[19] មេធាវីការពារក្ដីលើកឡើងពីវិធាន២៥ ដើម្បីគាំទ្រដល់សំអាងរបស់ខ្លួន។ **E224** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កំណត់សម្គាល់ជើងទំព័រលេខ២។ សហព្រះរាជអាជ្ញាសូមធ្វើការកត់សម្គាល់ថា វិធាន២៥ អនុវត្តចំពោះ “ជនសង្ស័យ ឬ ជនត្រូវចោទ”។ អឿន តាន គឺជាសាក្សីមួយរូប។

[20] **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី, កំណត់សម្គាល់*ខាងលើ* លេខ១២ ត្រង់កថាខណ្ឌទី១៤។

[21] **D107/2.1** ប្រតិចារឹកមួយចំណែកនៃសំណុំខ្សែអាត់សម្លេង D107/2R, ទំព័រ៤។

នោះចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ បានសង្ខេបនូវចំណេះដឹង និងសក្ខីកម្មរបស់សាក្សីយ៉ាងត្រឹមត្រូវ និងពិតប្រាកដ។ អឿន តាន បានបញ្ជាក់អំពីភាពត្រឹមត្រូវនៃចម្លើយនោះ ទាំងនៅ ពេលដែលគាត់បានផ្តល់នូវចម្លើយនោះ (ដោយផ្តិតមេដៃនៅគ្រប់ទំព័រនៃកំណត់ហេតុ) និងនៅពេល ដែលគាត់បានធ្វើសក្ខីកម្មនៅក្នុងតុលាការ[22]។ ដូច្នេះ ពុំមានមូលដ្ឋានណាមួយឲ្យមេធាវីការពារក្តីអះអាងថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនោះមិនមែនជាការឆ្លុះបញ្ចាំងពិតប្រាកដអំពីការស្តាប់ចម្លើយ កាលពី មុនដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នោះឡើយ។ ពុំមានការចង្អុលបង្ហាញ សោះ ឡើយថា សាក្សីនេះត្រូវបានគេបង្ខាប់ ឲ្យផ្តល់នូវព័ត៌មាន ឬក៏ជំរុញឲ្យផ្តល់នូវសក្ខីកម្មមិនពិតនោះ។ សរុប មកការចោទប្រកាន់ដោយមេធាវីការពារក្តីអំពីការបំភាន់ និង "ការផ្តិតស្នែក" គឺពុំមានមូលដ្ឋានទាល់តែសោះ។

17. ភាពមិនប្រក្រតីផ្នែកនីតិវិធីដែលមេធាវីការពារក្តីបានចោទប្រកាន់នោះ ពុំបង្កើតឲ្យមានភាពមិនស៊ីសង្វាក់អ្វីធំដុំនោះឡើយនៅក្នុងសក្ខីកម្មដែលបានផ្តល់ដោយសាក្សីរូបនេះ។ ការអនុវត្តណាមួយរបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ក្នុងការជជែកពិភាក្សាបឋមជាមួយនឹងសាក្សីនៅមុនពេលចាប់ផ្តើម ការស្តាប់ចម្លើយជាផ្លូវការ ដោយមានថតសំឡេងនោះ គឺមិនរំលោភទៅលើវិធានរបស់ អ.វ.ត.ក ឡើយ ហើយអាចធានានូវការប្រាស្រ័យទាក់ទងដ៏ល្អជាមួយសាមីសាក្សី និងធានាបានថាកំណត់ហេតុជាលាយលក្ខណ៍អក្សរកាន់តែត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយថែមទៀតផង។

### គ. មេធាវីការពារក្តីព្យាយាមគាំទ្រនូវអំណះអំណាងរបស់ខ្លួនដោយការសន្និដ្ឋានដែលពុំសមហេតុផល និងពុំមានមូលដ្ឋាន

18. ផ្នែកជាច្រើននៃសំណើរបស់មេធាវីការពារក្តីគឺផ្អែកទៅលើការសន្និដ្ឋានដែលពុំមានមូលដ្ឋាន និងបារម្ភជ្រុលហួសហេតុពេក។ ទោះបីជាមេធាវីការពារក្តីលើកឡើងថា មេធាវីការពារក្តី"*ពុំដឹង និងមិនអាចដឹង* ឡើយថាតើអ្នកស៊ើបអង្កេតបានប្រើប្រាស់ឯកសារណាមួយ ឬធ្វើសេចក្តីថ្លែងការណ៍ណាមួយដើម្បី ជួយជំរុញ

[22] **E3/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨, *មាននៅច្រើនកន្លែង*។ E1/86.1 ប្រតិចារឹក ទំព័រ១០ បន្ទាត់៤-៧, ទំព័រ៥១ បន្ទាត់១៦-២០។

ឬធ្វើឲ្យ អៀង សារី មានការនឹកឃើញឡើងវិញនោះ"[23] យ៉ាងណាក៏ដោយ ក៏មេធាវីការពារក្ដីអះអាងដោយពុំមានភ័ស្ដុតាងបន្ថិចសោះឡើយថា ៖

> *ការស្ដាប់ចម្លើយនេះទំនងជាមានការបង្ហាញឯកសារ និង/ឬព័ត៌មាននានាដល់រូប អៀង សារី ដើម្បី ធ្វើឲ្យគាត់នឹកឃើញសារជាថ្មី ឬជួយសម្រួលនូវការចងចាំថ្មីៗដែលនឹងត្រូវបានស្រង់យកជា ការចងចាំថ្មីៗវិញ។ និយាយម្យ៉ាងទៀតគឺថា តាមរយៈកិច្ចសម្ភាសន៍សួរនិងឆ្លើយដោយពុំបាន ថតសំឡេងរបៀបលាក់លៀមនេះ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានរៀបចំដើម្បីគ្រប់គ្រង និងបើចាំបាច់គឺបង្កើតសក្ខីកម្មសម្រាប់ អៀង សារី តែម្ដង*[24]។

19. គំនិតរវើរវាយគ្មានដែនកំណត់នេះបន្តអះអាងទៀតថា "ចេតនា និងគោលបំណងនៃកិច្ចសម្ភាសន៍ថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ គឺជាកិច្ចសម្ភាសន៍ សាកល្បង ដែលត្រូវបានបង្កើតឡើង និងធ្វើឲ្យមានឥទ្ធិពល/បំប្លែងចម្លើយ អៀង សារី ក្នុងការផ្ដល់បទសម្ភាសន៍ ដែលបានថតចម្លង... ពុំអាចមានការពន្យល់ណាដែលមានហេតុផលផ្សេងពីនេះ..."[25]។ ការប្រឌិតព័ត៌មានសុទ្ធសាធបែបនេះមិនអាចទទួលយកបានទេនៅចំពោះមុខអង្គជំនុំជម្រះនេះ។ អាស្រ័យហេតុនេះ វាមិនមានអ្វីត្រូវភ្ញាក់ផ្អើលឡើយថា មេធាវីការពារក្ដីបានដឹងខ្លួនឯង អំពីការអះអាងមិនត្រឹមត្រូវ និងមិនមានមូលដ្ឋានរបស់ខ្លួន ដែលនៅពេលនេះពួកគាត់គិតថាវាចាំបាច់ត្រូវអះអាងថា ការដាក់សំណើរបស់ពួកគាត់នេះ មិនមែន "ជាការយុទ្ធសាស្ត្រការពារក្ដីបែបបន្ទុចបង្អាក់កិច្ចដំណើរការនីតិវិធីតុលាការនោះទេ"[26]។

20. មេធាវីការពារក្ដីមិនត្រឹមតែមិនបានផ្ដល់នូវការគាំទ្រណាមួយចំពោះការចោទប្រកាន់អំពីការ ប្រព្រឹត្តកំហុសដោយចេតនានោះឡើយ ប៉ុន្តែជាក់ស្ដែងសកម្មភាពរបស់ ក.ស.ច.ស គឺជាការសន្មត អំពីភាពប្រក្រតីដែល

---

[23] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ៧ (គូសបញ្ជាក់បន្ថែមក្នុងឯកសារដើម)។

[24] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ៧។

[25] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ៨។

[26] **E224** សំណើ *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ១១។

មិនអាចបដិសេធបានឡើយនៅត្រង់ចំណុចនេះ[27]។ ការសន្និត់នេះ ត្រូវបានតម្កល់នៅ ពេលណាបណ្តឹងត្រូវបានចាត់ទុកថាជាបណ្តឹងដែលផ្អែកលើការសន្និដ្ឋាន ឬគ្មានភ័ស្តុតាង"[28]។

## III. សេចក្តីសន្និដ្ឋាន

21. ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងអង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកព័ត៌មានបន្ថែមទៀតដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍ និងសមហេតុផលពី ក.ស.ច.ស ទាក់ទិននឹងការប្រាស្រ័យទាក់ទង អៀន តាន នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ នោះឡើយ ប៉ុន្តែសូមបដិសេធនូវរាល់ការអះអាងបន្ថែម និងទទ្ទីករណ៍ទាំងអស់ ដែលមាននៅក្នុងសំណើ។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២ | **លោក យ៉េត ចរិយា**<br>**សហព្រះរាជអាជ្ញារង** | | [signature] |
| | **William SMITH**<br>**សហព្រះរាជអាជ្ញារង** | | [signature] |

[27] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី *យោងខាងលើ* កំណត់សម្គាល់១២ ត្រង់កថាខណ្ឌ១០ ("នៅពេលដែលការតវ៉ាអំពីភាពត្រឹមត្រូវនៃទង្វើរបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ឬនៅពេលមានការចោទប្រកាន់អំពីការបំប្លែង ឬការបង្ខូចភស្តុតាង ម្ចាស់បណ្តឹងនឹងទទួលបន្ទុក ក្នុងការបង្ហាញថា ការសន្មតថាសកម្មភាពរបស់ ក.ស.ច.ស មានភាពប្រក្រតី ពុំគួរយកមកអនុវត្តតទៅទៀតឡើយ។") ។

[28] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី *យោងខាងលើ* កំណត់សម្គាល់១២ ត្រង់កថាខណ្ឌ១០។